**BMI0065**

# សម្ភាសន៍ជាមួយឈ្មោះ អ៊ីង ហ៊ិន ភេទប្រុស អាយុ៥៥ឆ្នាំ

**មុខងារជំនាន់ខ្មែរក្រហមៈ “យោធា”**

**មុខងារបច្ចុប្បន្នៈ “កសិករ”**

**ស្រុកកំណើតនៅឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ**

**រស់នៅភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ សោម ប៊ុនថន**

**០០ៈ៣៩ៈ៥៣**

**១៨ទំព័រ**

ប៊ុនថនៈ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូ លោកពូឈ្មោះអីដែរ?

ហ៊ិនៈ ខ្ញុំឈ្មោះ អ៊ីង ហ៊ិន ។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយ?

ហ៊ិនៈ ខ្ញុំអាយុ៥៥ហើយ ។

ប៊ុនថនៈ ពូមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ហ៊ិនៈ ស្រុកកំណើតពីដើមមកតែម្ដង ។

ប៊ុនថនៈ បាទ!ស្រុកកំណើតពីដើមមក?

ហ៊ិនៈ នៅខេត្តតាកែវ ស្រុកត្រាំកក់ ឃុំត្រពាំងធំខាងជើង ។

ប៊ុនថនៈ ខេត្តតាកែវ ពូមកដល់នេះដំបូងឆ្នាំណាពូ?

ហ៊ិនៈ មកដល់នេះដំបូងនៅឆ្នាំ៨៣ ។

ប៊ុនថនៈ ចឹង៨៣មកដល់ម៉ាឡៃនេះពូ?

ហ៊ិនៈ បាទ ។

ប៊ុនថនៈ មកដល់ភូមិនេះតែម្ដងឬពូមកនៅកន្លែងផ្សេង?

ហ៊ិនៈ កាលមកដល់ដំបូងនៅមាត់អូរតែម្ដង ជាប់ព្រំដែនថៃតែម្ដង ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ពីនេះទៅប្រហែលជាមួយគីឡូ ។

ប៊ុនថនៈ តែនៅភូមិឃុំបឹងបេងហ្នឹងពូ?

ហ៊ិនៈ កាលពូមុនគេមិនទាន់រៀបជាឃុំបឹងបេងអីទេ កាលពីជំនាន់ហ្នឹង ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ឃុំបឹងបេងហ្នឹងទើបរៀបចំកាលសម័យដាច់ខ្លួនហ្នឹងទេ ។

ប៊ុនថនៈ កាលពូមកនៅហ្នឹង មកនៅច្រើនគ្នាទេពូ?

ហ៊ិនៈ ច្រើនកាលហ្នឹងច្រើន តែវាមិនច្រើនដូចឥឡូវពេកទេ ។

ប៊ុនថនៈ បាទ!រត់មកសុទ្ធតែប្រជាជន កាលដែលរត់មក?

ហ៊ិនៈ កាលហ្នឹងមានប្រជាជនមានទាហានខ្លះ មានអីខ្លះតែខ្ញុំមិនដែលធ្វើទាហានហ្នឹងគេផង កាលសម័យហ្នឹងពីមុនមកបានខ្ញុំដែលធ្វើ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ខ្ញុំឈប់ហើយកាលសម័យហ្នឹង ។

ប៊ុនថនៈ ចឹងពូរត់ពីណាមក?

ហ៊ិនៈ ខ្ញុំហ្នឹង ។

ប៊ុនថនៈ បាទ!មុនមកដល់ហ្នឹង?

ហ៊ិនៈ មុនហ្នឹងខ្ញុំកាលសម័យខ្មែរក្រហមហ្នឹងធ្វើទ័ពហ្នឹងចេញពីទន្លេសាបហ្នឹងខ្ញុំទៅស្រុកទៅនៅជាមួយខាងរដ្ឋកម្ពុជាដែលហ្នឹង ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ដល់ការហើយបានខ្ញុំវិញមកខាងនេះវិញ ខ្មែរក្រហមវិញ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ពូខ្ញុំនៅទីនេះ ខ្ញុំមកនៅជាមួយគាត់វិញទៅ មកកាលនៅលំបាកសភាពការណ៍តឹងតែងមក កាលហ្នឹងរត់លូនផងបានទៅដល់ខ្មែរក្រហមវិញ មកហ្នឹងក៏មិនមកកន្លែងនេះដែលពីដើមមក ហ្នឹងគេហៅភ្នំឆ័ត្រព្រៃមាន់អីជើងណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ កាលហ្នឹងគេហៅថាឃួនអីវ៉ែអាព្រៃមាន់ភ្នំឆ័ត្រហ្នឹងក៏គេជម្លៀសរត់យកមកនៅនេះ ។

ប៊ុនថនៈ ព្រៃមាន់ហ្នឹងនៅម្តុំណាទៅ?

ហ៊ិនៈ ខេត្តបន្ទាយមានជ័យដែលហ្នឹង ស្រុកថ្មពួក ។

ប៊ុនថនៈ ស្រុកថ្មពួក?

ហ៊ិនៈ បាទ ។

ប៊ុនថនៈ ចឹងកាលពូចេញមកនេះទាំងគ្រួសារពូ?

ហ៊ិនៈ បកទាំងអស់គ្នាហ្នឹង បងប្អូនទាំងអស់មកពីហ្នឹងមក ថាទាំងអស់គ្នាហ្នឹងតែម្ដងអ្នកនៅនេះ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ មកនៅកន្លែងនេះឆ្នាំ៨៥ ឆ្នាំ៨៥នេះគេរើកន្លែងនេះទៀតចូលទៅនៅថៃ ។

ប៊ុនថនៈ នៅថៃនៅម្ដុំណាពូ?

ហ៊ិនៈ នៅជិតនេះដែរ នៅ៨៥ ជំរំ៨៥នេះខាងលិច ។

ប៊ុនថនៈ ទៅពីនេះទៅប៉ុន្មានគីឡូ?

ហ៊ិនៈ ប្រហែលជាដប់បួនគីឡូដែលដឹង ខ្ញុំប៉ុណ្ណឹងឯងមិនដែលបានដើរកាត់ហ្នឹងផង កាលជំនាន់ហ្នឹងទៅមកឡាន ព្រោះឆ្លងថ្នល់ជាតិទី៧ ។

ប៊ុនថនៈ កាលពូរត់ទៅហ្នឹងពូមានកូនហើយនៅ?

ហ៊ិនៈ ខ្ញុំកាលរត់មកពីភ្នំឆ័ត្រហ្នឹងមានកូនមួយហើយ ដល់ទៅនៅដីថៃហ្នឹងបានកូនពីរទៀតកូនបីនាក់ ។

ប៊ុនថនៈ ពូនៅហ្នឹងប៉ុន្មានបានពូត្រឡប់មកនៅភូមិនេះវិញ?

ហ៊ិនៈ កាលហ្នឹងនៅដីថៃ កាលហ្នឹង៥ឆ្នាំកាលហ្នឹង ៥ទៅ៦មិនបានរាប់ភ្លេចហើយ ចេញពី៨៥នេះទៅនៅដងរែកដុបគគីរណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ នៅហ្នឹងទៀតដល់ហើយ មុនផ្ដាច់ខ្លួនហ្នឹងខាងដុបគគីរហ្នឹងខាងប៉ារាហ្នឹងកាលហ្នឹងត្រូវជាមួយទាហានខាងក្នុងក៏រើទាហានខ្មែរក្រហមហ្នឹងទៀត ចឹងចេញពីហ្នឹងមក មកនៅនេះវិញនៅកន្លែងខ្មែរក្រហមហ្នឹងវិញទាំងអស់គ្នាហ្នឹង ។

ប៊ុនថនៈ ចឹងរត់ពីដុបគគីរមកនេះ?

ហ៊ិនៈ បាទ!មកនេះវិញ ។

ប៊ុនថនៈ ចឹងមកដល់នេះនៅឆ្នាំណាពូ?

ហ៊ិនៈ ឆ្នាំ៩០ប៉ុន្មានទេ កាលហ្នឹងខ្ញុំឆ្នាំ៩៥ប៉ុណ្ណឹងឯង មុនផ្ដាច់ខ្លួនពីរឆ្នាំ ។

ប៊ុនថនៈ ចឹង៩៨?

ហ៊ិនៈ បាទ!ខ្ញុំ៣៩-៩៨ហ្នឹងឯង ។

ប៊ុនថនៈ ចឹងបានពូរស់នៅភូមិនេះរាល់ថ្ងៃនេះ?

ហ៊ិនៈ បាទ ។

ប៊ុនថនៈ គេចែកឲ្យពូដីនេះ?

ហ៊ិនៈ ដីនេះពួកខ្ញុំរស់នៅដើម ដីនេះគេមានបានចែកណាស្មុគ្រតែទិញ ទិញទាំងអស់ហ្នឹងទិញកេ អ្នកនៅមុន ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ទិញកាលហ្នឹងនៅថោកទេ កាលហ្នឹងមានពីរវគ្គ ខ្លះចេញពី៨៥ហ្នឹងខ្លះគេទៅដើមទៅតាម អន្តភាពនរណាគេអត់ទៅដើមគេចូលមកនេះមកដីគេចែក ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ គេចែកឲ្យមួយប្លង់ៗម្នាក់ចឹងទៅ គេទៅតាមអន្តភាពរៀងៗខ្លួនទៅកាលជំនាន់ហ្នឹង ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ គេមានកងមានក្រុមគេ ។

ប៊ុនថនៈ ពេលដំបូងពូមកដល់កាល៨៣ហ្នឹងមានប្រជាជនមករស់នៅច្រើនទេ នៅម៉ាឡៃហ្នឹង?

ហ៊ិនៈ មាន មានគេរត់តាំងពី៧៩ក៏គេមាននៅហ្នឹង នៅផ្សារម៉ាឡៃហ្នឹងពីដើមគេហៅភូមិដូងៗ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ មានគេនៅកាលហ្នឹង ប្រជាជនគេអ្នករត់មកនៅហ្នឹង ពួកខ្ញុំនៅម៉ាជួរឃុំបឹងបេងនេះមក ក្រោយទេ ។

ប៊ុនថនៈ មកក្រោយ?

ហ៊ិនៈ បាទ!មកពីដើមមកទេ ពេលគេរើនៅដើមទៅរដ្ឋគេយកមកនេះមក កាលជំនាន់ហ្នឹង ។

ប៊ុនថនៈ ចឹងកាលមកដល់ហ្នឹងភូមិហ្នឹងគេហៅបឹងបេងហើយនៅពូ?

ហ៊ិនៈ ហៅបឹងបេង កាលពីមុនគេអត់ហៅបឹងបេងទេ គេហៅភូមិដូងតែមួយ ដល់ក្រោយមក បានគេរៀបចំមានភូមិបឹងបេងមានអីចឹងទៅ ។

ប៊ុនថនៈ បាទ!ម៉េចបានគេហៅបឹងបេងពូ?

ហ៊ិនៈ មិនដឹងយ៉ាងម៉េចទេ គេដាក់ឈ្មោះចឹងទៅ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ បឹងបេងហ្នឹងជាឃុំទេ ភូមិគេហៅភូមិចំបក់ ។

ប៊ុនថនៈ ចឹងចំបក់កើតក្រោយដែរ?

ហ៊ិនៈ កើតក្រោយដែលទេ ។

ប៊ុនថនៈ ចឹងពូមានដឹងប្រវត្តិទេយ៉ាងម៉េចបានជាដាក់ឈ្មោះភូមិចំបក់អី?

ហ៊ិនៈ ខ្ញុំមិនដឹងទេនេះ ខ្ញុំមិនដឹងសោះ ។

ប៊ុនថនៈ ចឹងពូមកដល់នេះកាលឆ្នាំ៨៣?

ហ៊ិនៈ បាទ ។

ប៊ុនថនៈ កាលឆ្នាំ៨៣ពូធ្វើអីវិញពូមកដល់ដំបូង?

ហ៊ិនៈ ខ្ញុំអត់មានធ្វើអីផងខ្ញុំធ្វើប្រជាជន ។

ប៊ុនថនៈ ពូអត់នៅកងទេ?

ហ៊ិនៈ អត់ ខ្ញុំអត់មានធ្វើទាហានហ្នឹងគេផង ធ្វើប្រជាជន ។

ប៊ុនថនៈ ចឹងគ្រួសារលោកពូ?

ហ៊ិនៈ ហ្នឹងក៏អត់មានធ្វើអី ។

ប៊ុនថនៈ តែធ្វើរករបររកស៊ីអីទៅ?

ហ៊ិនៈ មកកាលហ្នឹងអត់មានរកស៊ីអីផង ព្រោះយើងប្រជាជនរដ្ឋគេបើកអង្ករឲ្យហូប ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ហើយគេមានឲ្យយើងទៅដើរស៊ីឈ្នួលគេអីណា គេមិនឲ្យធ្វើទេ ព្រោះប៉ះពាល់ទាហានគេ ទៅមុខណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ កុំឲ្យថាយើងនៅក្រោយរកស៊ីទៅវាប៉ះពាល់ដល់ចឹងទៅគេអត់មានឲ្យរកស៊ីអីទេ ចុះមានគិតគូររឿងចាយវាយអីបើរដ្ឋបើកឲ្យគ្រប់មុខ កាលជំនាន់ហ្នឹង ។

ប៊ុនថនៈ មានហូបគ្រប់ដែលកាលហ្នឹងពូ?

ហ៊ិនៈ គ្រប់មិនដែលខ្វះទេ ។

ប៊ុនថនៈ គេបើករបៀបម៉េច?

ហ៊ិនៈ គេបើកអង្ករ អំបិល ប៊ីចេងអីហ្នឹង ត្រីខអីហ្នឹង ។

ប៊ុនថនៈ គេបើតាមសមាជិកគ្រួសារឬយ៉ាងម៉េច?

ហ៊ិនៈ គេបើកតាមសមាជិកគ្រួសារ បើមានប្អូនទាក់ចឹងគេឲ្យតាមហ្នឹងទៅ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ហូបមិនអស់ទេ អង្ករអីវ៉ាន់ហ្នឹង ឈានដល់លក់អី យើងធ្វើបានខ្លះដែលដូចជាដាំពោតធ្វើស្រូវធ្វើអីបាន យើងធ្វើអង្ករអស់ហ្នឹងបានយើងធ្វើលក់ទៅណាស់ យកលក់ឲ្យថៃយកលុយចាយទៅ ។

ប៊ុនថនៈ ចឹងយើងបានលក់អត់មានទុកហូបខ្លួនឯងទេ?

ហ៊ិនៈ កាលជំនាន់ហ្នឹងអត់ទេ ព្រោះមានកាកក្របាតបើកជំនាន់ហ្នឹង កាកក្របាតគេមកបើកមានប៉ុ៉ងគេបើកណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ជំនាន់កាកក្របាតទេ កាលហ្នឹង ។

ប៊ុនថន៖ គេបើកនៅណាវិញ?

ហ៊ិន៖ នេះកន្លែងគេបើកនៅអូរខាងលិចនេះ ផ្លូវនេះទៅចំតែម្តងឆ្លងអូរម្ខាងបើកនៅដីថៃ ។

ប៊ុនថន៖ បើកនៅដីថៃ?

ហ៊ិន៖ បាទ!មួយអាទិត្យបើកម្តងចឹងទៅ ។

ប៊ុនថន៖ ចឹងមួយអាទិត្យទៅបេូកម្តង?

ហ៊ិន៖ បាទ!មួយអាទិត្យគេមកបើកឲ្យម្តង ។

ប៊ុនថន៖ ចឹងពូនៅនេះនៅយូរដែរពី៨៣ដល់?

ហ៊ិន៖ នៅយូរដែរ ពូដំបូងនៅ៨៣ទេ តែដល់ទៅនៅថៃ៥ទៅ៦ឆ្នាំទៅ ទៅនៅជើងនោះប៉ុន្មានឆ្នាំទៅបានបកមកនៅនេះវិញ នេះច្រើនណាស់ កាលជំនាន់ហ្នឹងកន្លែងណានេះដើរគ្រប់កន្លែងហ្នឹង ។

ប៊ុនថន៖ ចឹងទៅថៃហ្នឹងពូនៅធ្វើអី នៅហូបរបបបើកដីដែល?

ហ៊ិន៖ ហ្នឹងហើយទៅថៃរបបបើក ហ្នឹងលែងកាកក្របាតហើយរដ្ឋគេបើកតែម្តង ហ្នឹងលែងខុះតែម្តង អង្ករហ្នឹងបើកពេញៗការ៉ុងមក ។

ប៊ុនថន៖ រដ្ឋខាង?

ហ៊ិន៖ ខាងខ្មែរក្រហមហ្នឹងណាស់ ។

ប៊ុនថន៖ ប្រជាជនច្រើនទេ នៅជំរំ?

ហ៊ិន៖ នៅជំរំហ្នឹង ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ច្រើនកាលហ្នឹង ។

ប៊ុនថន៖ ប្រហែលជាប៉ុន្មាននាក់ទៅទាំងអស់?

ហ៊ិន៖ ច្រើននាក់ដែលហ្នឹងម៉ាភូមិៗ នៅប៉ុន្មានឃុំនោះហ្នឹង នៅពីរឃុំ កាលយើងនៅ៨៥មនុស្សច្រើនណាស់កាល ។

ប៊ុនថន៖ រាប់រយនាក់?

ហ៊ិន៖ ទេ រាប់លពាន់នាក់នោះ ។

ប៊ុនថន៖ បាទ ។

ហ៊ិនៈ កាលហ្នឹងចេញមកវិញនៅជាមួយគ្នាពួកភូមិដូងស្អីហ្នឹងមូលគ្នាទាំងអស់ហ្នឹង និយាយរួមអ្នកនៅព្រំដែនឲ្យតែអ្នកនៅចាស់នៅហ្នឹងទាំងអស់ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ហើយភាគច្រើន ច្រើនចាស់ហើយនៅតាមថ្នល់ហ្នឹង ផ្ទះធំៗនេះសុទ្ធតែពួកចាស់ហើយ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ចាស់ រហូតទៅដល់ខ្វាងរាប់ទៅអីនោះ ពេញហ្នឹងទាំងអស់ ។

ប៊ុនថនៈ ទាំងអស់ទៅនៅហ្នឹង?

ហ៊ិនៈ បាទ!ពួកចាស់សុទ្ធតែនៅយូរហើយ អ្នកនៅថ្មីមានភាគតិចទេ យ៉ាងច្រើនមានម្នាក់មួយគ្រួសារពីរគ្រួសារអីហ្នឹង ហ្នឹងអ្នកនៅថ្មីណាស់ មកកាលផ្តាច់ខ្លួនហើយ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ មានតិចទេ ។

ប៊ុនថនៈ ចឹងពូថាត្រឡប់មកពីដីថៃថាមកនៅនេះវិញ ហើយបានចេញទៅ?

ហ៊ិនៈ អត់ទេ មកពីដីថៃឡានគេដឹកយកទៅដាក់នៅភ្នំឆត្រតែម្តង ។

ប៊ុនថនៈ ដាក់នៅភ្នំឆត្រ?

ហ៊ិនៈ ដាក់នៅជុបគគីរ ។

ប៊ុនថនៈ ជុបគគីរភ្នំដងរែកហ្នឹង?

ហ៊ិនៈ បាទ!ចេញពីដងរែកបានមកនេះវិញ កាលប៉ារាហើយនិងទាហានខាងក្នុងត្រូវគ្នាគេមិនរើ កាលហ្នឹងមានដែលពុសូរ្យទេ ជំនាន់ហ្នឹងមានដឹងទេ កាលហ្នឹងឆ្នាំ៩៣-៩៤ហ្នឹង ។

ប៊ុនថនៈ បាទ!ពុប៉ារា ។

ហ៊ិនៈ ជំនាន់ហ្នឹងហើយខ្លះគេទៅនៅស្រុកខ្មែរវិញទៅ ខ្លះគេចូលជំរំកងវ៉ាយនោះទៅ ខ្លះដឹងថាទៅរកស៊ីណាអីណី អត់មានផ្ទះអត់មានដីមានធ្លីអីក៏គេបកមកនេះមកចូលតាមច្រកជិតប៉ោយប៉ែតនេះ កាលហ្នឹងគេឲ្យចេញចូលតាមហ្នឹង ។

ប៊ុនថនៈ តាមអូរជ្រៅហ្នឹង?

ហ៊ិនៈ អត់ទេ ចេញកន្លែងគោកស្បែងអត់មានដល់អូរជ្រៅទេ បែបវត្តគោកស្បែងនេះ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ មកជិះម៉ូតូជិះអីមក កាលហ្នឹងគេមានបិតអីនៅចេញចូលបាន ។

ប៊ុនថនៈ ចេញពីថៃចូលខ្មែរ?

ហ៊ិនៈ អត់ទេ ចេញពីខ្មែរយើងមកនេះតែម្តងហ្នឹង ទាហានខ្មែរមានឃាត់ណា ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ឲ្យមក មកនៅនេះវិញជាមួយខ្មែរក្រហមនេះវិញទៀតទៅ ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ បើយើងធ្លាប់នៅនេះ បើយើងទៅនោះអត់មានដីមានធ្លីដីងពីងអីណា មកនៅហ្នឹងវិញគ្រប់គ្នាហ្នឹងទៅ ។

ប៊ុនថន៖ មកនៅនេះថាមានបងពូមកជាមួយពូវិញដែរ?

ហ៊ិន៖ បាទ!អត់ទេ បកពីហ្នឹងទាំងអស់គ្នា ។

ប៊ុនថន៖ មកនៅនេះ៩៤ហើយពូ?

ហ៊ិន៖ ហ្នឹងហើយ៩៤ហើយ ។

ប៊ុនថន៖ ចឹងពូមកដល់បានពីរឆ្នាំបានសមាហរណ៍កម្ម?

ហ៊ិន៖ បាទ!៩៦ ។

ប៊ុនថន៖ ចឹងសមាហរណ៍កម្មកាល៩៦ហ្នឹងនិយាយថាពូមានទិញដីធ្វើផ្ទះដែលពូ?

ហ៊ិន៖ កាលមកហ្នឹងដីសុទ្ធតែទិញគេ យើងអ្នកមកក្រោយ បើគេនៅមុនគេអត់ទេ គេចែក កាលនៅសង្គ្រាមចេះតែចែកដីគ្នានៅបានទៅ ដល់ផ្តាច់ខ្លួនបានហ្នឹងយើងទិញនៅរៀងៗខ្លួនទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ខ្ញុំសុទ្ធតែទិញគេមកក្រោយនោះ ។

ប៊ុនថន៖ តែកាលមកហ្នឹងមានចាប់ខ្លួនឯងនៅបានទេ?

ហ៊ិន៖ កាលហ្នឹងគេមកនៅមុនហើយហ្នឹង ពួកខ្ញុំមកក្រោយ អ្នកមកមុនគេបាន ដីហ្នឹងសុទ្ធតែទិញគេទេ ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ មកក្រោយទិញគេ ទិញគេកាលនោះមិនមែនថ្លៃដូចឥឡូវទេ កាលហ្នឹងវានៅថោក ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ម៉ារ៉ៃពីរបីពាន់បាតអីហ្នឹង ។

ប៊ុនថន៖ ចុះឥឡូវពូមានចំការដែរ?

ហ៊ិន៖ មាន ។

ប៊ុនថន៖ មានប៉ុន្មានដែរ?

ហ៊ិន៖ ខ្ញុំមានបន្តិចហ្នឹងមានតែ៥ហិចតា ។

ប៊ុនថន៖ ធ្វើស្រែឬធ្វើចំការ?

ហ៊ិន៖ ដាំដំឡូងទាំងអស់ ។

ប៊ុនថន៖ និយាយចឹង កាលពូមកកាលឆ្នាំ៨៣ហ្នឹងនៅម៉ាឡៃហ្នឹងមានព្រៃមានអីទេ?

ហ៊ិន៖ ៨៣មានព្រៃ កាលជំនាន់៨៣គេមានផ្លូវធ្វើតាមមាត់អូរ ។

ប៊ុនថន៖ ចឹងខាងនេះអត់មានផ្លូវទេ?

ហ៊ិន៖ ខាងនេះអត់មានទេ ខាងនេះព្រៃសុទ្ធតែម្ដង ហើយរឿងកាប់ឆ្កាក៏មិនទាន់មានកាប់ដែលអត់ទេ កាប់តែបន្តិចក្បែរៗផ្ទះទេ ផ្លូវគេមានតាមមាត់អូររហូតតាំងពីភូមិដូងហ្នឹងទៅរហូតដល់ស្រុកសំពៅលូន ស្រុកភ្នំព្រឹកចឹងទៅ ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ គេនៅតាមហ្នឹងរហូតទៅ ។

ប៊ុនថន៖ ចឹងមានតែផ្លូវតាមមាត់អូរនេះព្រៃជិត?

ហ៊ិន៖ បាទ! ព្រៃ ។

ប៊ុនថន៖ ព្រៃក្រាស់តែម្ដងពូ?

ហ៊ិន៖ ព្រៃស្រុកនេះ ព្រៃក្រាស់ណែនតែម្ដង មិនមែនព្រៃភ្លើងឆេះណា ភ្លើងអត់ឆេះទៀតភ្លើងនោះ មិនមែនព្រៃព្រិចណា ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ព្រៃដើមឈើដុះណែន តែឥឡូវរកមិនបានទេកាប់ខ្ទិចអស់ហើយធ្វើចំការ ។

ប៊ុនថន៖ ចឹងផ្លូវនេះកើតនៅឆ្នាំប៉ុន្មានដែរ?

ហ៊ិន៖ ផ្លូវនេះធ្វើផ្ដាច់ខ្លួនហើយ ផ្លូវនេះមិនដឹងជាធ្វើកាលទេ ព្រោះពួកខ្ញុំនៅជុបគគីរ ។

ប៊ុនថន៖ ចឹង៨៣អត់ទាន់មានទេ មានតែផ្លូវមាត់អូរ?

ហ៊ិន៖ ៨៣មានតែផ្លូវមាត់អូរ ពីដើមធ្វើតាមមាត់អូររហូត៨៣ហ្នឹង ប្រជាជននៅតាមហ្នឹងរហូតមាត់អូរហ្នឹងតែម្ដង ។

ប៊ុនថន៖ ឡានអីបរតាមផ្លូវមាត់អូរហ្នឹងតែម្ដង?

ហ៊ិន៖ ឡាន កាលហ្នឹងមិនសូវមានឡានមានតែឡានចិនមួយៗ មានម៉ូតូណាកាលហ្នឹងនោះ ប្រជាជនយើងមានពីណាមានអី ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ដើរហ្នឹង ។

ប៊ុនថន៖ ចឹងកាល៨៣ហ្នឹងយ៉ាងម៉េចបានជាពូទៅនៅជំរំហ្នឹងពូ?

ហ៊ិនៈ កាលឃ្មួនវ៉ៃនៅនេះ៨៥ មកពីដើងមកយើងមិនមក៨៣កាលហ្នឹងវ៉ៃនៅគ្រួសក្រហម ៨៥នេះឃ្មួនវ៉ៃទាំងអស់ព្រំដែននេះ យើងចូលថៃទាំងអស់ចូលជំរំតាង៉ុក គេហៅជំរំសាយអេកនោះ ។

ប៊ុនថនៈ ជំរំសាយអេក?

ហ៊ិនៈ ហ្នឹងហើយចូលទៅជំរំហ្នឹងទៅ ពួកណានៅក្នុងអង្គភាពណាគេយកមកវិញ រដ្ឋគេយកមកវិញមិនឲ្យនៅជាមួយប្រជាជនច្របូកច្របល់ហ្នឹងទេណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ យកមកវិញ មកឲ្យនៅជំរំ៨៥នេះ ។

ប៊ុនថនៈ ចឹងបើមានអ្នកណានៅកងអីយកមកជំរំ៨៥នេះ?

ហ៊ិនៈ បាទ ។

ប៊ុនថនៈ ចឹងនរណាអត់អី?

ហ៊ិនៈ ហ្នឹងគេនៅជំរំទៅ ។

ប៊ុនថនៈ ចឹងនៅជំរំសាយអេកទៅ?

ហ៊ិនៈ បាទ!ណាគេអត់ចេញគេនៅហ្នឹងទៅ ណាគេមានខ្សែគេនៅតាមកងក៏មកៗនៅនោះគេក៏មានថាអីយើងដែរ យើងមិនមកក៏គេមិនថាអី មិនថាអីទេកាលហ្នឹងនោះ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ កាលហ្នឹងខាងកាកក្របាតគេចិញ្ចឹម ។

ប៊ុនថនៈ ចឹងពូនៅជំរំសាយអេក?

ហ៊ិនៈ បាទ ។

ប៊ុនថនៈ អត់មក៨៥ទេ?

ហ៊ិនៈ មក ចេញពីសាយអេកហ្នឹងមក៨៥ ខ្ញុំនៅហ្នឹងបានប៉ុន្មានខែចូលខែ៣-៤ដល់ខែ៨ចេញចេញពីជំរំសាយអេកណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ ចេញពីសាយអេកហ្នឹងមកនៅជំរំ៨៥នេះ ។

ប៊ុនថនៈ ប្រហែលជាប៉ុន្មានគីឡូពីហ្នឹងទៅ?

ហ៊ិនៈ ប្រហែលជា១៩គីឡូនោះ ។

ប៊ុនថនៈ មើលទៅជិតដែរ?

ហ៊ិនៈ ហ្នឹង ។

ប៊ុនថន: ចឹងពូខាងកងជ្រើសរើសទៅវិញឬក៏បញ្ជូនទៅតែម្តង?

ហ៊ិន: អត់ទេ ទៅតាមអង្គភាពវិញ ។

ប៊ុនថន: កាលហ្នឹងនៅអង្គភាប៉ុន្មាន?

ហ៊ិន: កាលហ្នឹងកងពល៥១៩ ខ្ញុំអត់មានធ្វើទាហានអីគេទេ តែមានកូនអីធ្វើនៅក្នុងហ្នឹងខ្ញុំតាមបងប្អូនហ្នឹងណាស់ ។

ប៊ុនថន: បាទ ។

ហ៊ិន: ឈ្មោះខ្ញុំទាហានអត់ហ្នឹងគេទេ ។

ប៊ុនថន: បាទ ។

ហ៊ិន: ស្រេចចិត្តយើងមិនធ្វើតែយើងនៅជាមួយបងប្អូនយើងហ្នឹង មានអីកាលហ្នឹងជួយដឹកជញ្ជូនអីហ្នឹងណាស់ ។

ប៊ុនថន: បាទ! ហើយមានបានរបបដូចគ្នាទេ?

ហ៊ិន: ដូចគ្នា ។

ប៊ុនថន: កាលនៅជុបហ្នឹងមានវ៉ៃគ្នាខ្លាំងទេពូ?

ហ៊ិន: អត់ទេ ទៅដើងហ្នឹងអត់មានវ៉ៃផង ប្រជាជនចុះមកនៅក្រោយ ទ័ពគេនៅមុខណាស់ ។

ប៊ុនថន: បាទ ។

ហ៊ិន: តែកាលហ្នឹងដឹខ្មែរក្រហមរំដោះបានធំដែរ រំដោះបានស្រុកថ្មពួកមួយទាំងមូលហើយនៅស្រុកអំពិល ស្វាយចេកខ្មែរក្រហមនៅពេញវាលហ្នឹង ។

ប៊ុនថន: ចឹងខាងកំលាំងខ្មែរក្រហមគ្រប់គ្រង?

ហ៊ិន: បាទ! ទើបប៉ាពត្រូវគ្នាជាមួយទាហានខាងក្នុងតើ បានវ៉ៃហ្នឹង វ៉ៃភ្នំឆត្រវ៉ៃអីហ្នឹងបានរតាត់រតាយទៀតទៅហ្នឹង កាលមុនអត់ទេ ។

ប៊ុនថន: កាលមុនភ្នំឆត្រនៅស្រុកថ្មពួកដែរ?

ហ៊ិន: ភ្នំឆត្រនៅស្រុកថ្មពួក ។

ប៊ុនថន: វ៉ៃហើយបានពួរត់មកនេះ?

ហ៊ិន: បាទ! វ៉ៃហើយបានមកនេះ ។

ប៊ុនថន: ចឹងចង់សួរពូបន្តិចទាក់ទងស្រុកកំណើតពូមានបានរៀនអីដែលពូ?

ហ៊ិន: ខ្ញុំរៀនបានតិចតួចអទ់ចេះផង ។

ប៊ុនថន: រៀនដល់ថ្នាក់ទីប៉ុន្មានលោកពូ?

ហ៊ិន: កាលហ្នឹងមានបានរៀនអីចេះតិចតួចសើច... ។

ប៊ុនថន៖ ចុះពូនៅជាមួយឪពុកម្តាយរហូតពូ?

ហ៊ិន៖ ខ្ញុំចេញពីឪពុកម្តាយតាំងពីឆ្នាំ៧៣ ខ្ញុំធ្វើទាហាន កាលខ្មែរក្រហមមិនត្រូវជ្រើសរើសទៅ ។

ប៊ុនថន៖ បាទ!ចឹងចូលកង?

ហ៊ិន៖ បាទ!ចូលកងតាំងពីឆ្នាំ៧៣ ខ្ញុំបែកពីម្តាយតាំងពីអាយុ១៧ឆ្នាំ ។

ប៊ុនថន៖ ចឹងបងប្អូន?

ហ៊ិន៖ បងប្អូនកាលខ្ញុំចេញមកនៅជាមួយម៉ែឪហ្នឹង ។

ប៊ុនថន៖ បងប្អូនមានប៉ុន្មាននាក់ពូ?

ហ៊ិន៖ បងប្អូនខ្ញុំមានច្រើនណាស់ ស្លាប់អស់ហើយនៅសល់៥នាក់ ៥-៦នាក់ ។

ប៊ុនថន៖ ស្លាប់អស់ប៉ុន្មាននាក់?

ហ៊ិន៖ ស្លាប់អស់៣នាក់ ។

ប៊ុនថន៖ ចឹងស្លាប់៣នៅសល់៦នាក់?

ហ៊ិន៖ បាទ ។

ប៊ុនថន៖ ចឹងមាន៩នាក់បងប្អូន?

ហ៊ិន៖ បាទ!វាចេះទេបានច្រើនវាមិនមែនម៉ែឪតែមួយណា បើគិតម៉ែឪតែមួយ នៅបងប្អូនតែ៥នាក់ទេ ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ដល់ពេលម៉ែស្លាប់ទៅ ឪទៅយកប្រពន្ធក្រោយទៀតបានកូនពីរបីទៀត ។

ប៊ុនថន៖ ចឹងពូចេញពីផ្ទះរហូតចាប់តាំងពី៧៣ហ្នឹង?

ហ៊ិន៖ កាលហ្នឹងចេញពីផ្ទះរហូត ។

ប៊ុនថន៖ ដំបូងពូទៅខាងណាពូ?

ហ៊ិន៖ ចូលកងទ័ពតំបន់ខេត្តតាកែវ ។

ប៊ុនថន៖ កាលហ្នឹងគេហៅតំបន់ប៉ុន្មាន?

ហ៊ិន៖ តំបន់១៣ ។

ប៊ុនថន៖ តំបន់១៣ហ្នឹងមានស្រុកអីខ្លះពូ?

ហ៊ិន៖ ស្រុកច្រើនដែលតាកែវមើល ឥឡូវស្រុកថ្មីទៀតស្គាល់មិនសូវសព្វទៀត ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ មានត្រាំកក់ មានស្រុកទ្រាំង ស្រុកគីរីវង្ស ស្រុកកោះអណ្តែត ស្រុកបូរីជលសារ ស្រុកដូនកែវ ស្រុកព្រៃកប្បាស ស្រុកបាទី ស្រុកអង្គរបូរី ។

ប៊ុនថន៖ ចឹងតាកែវហ្នឹងនៅក្នុងតំបន់១៣ទាំងអស់?

ហ៊ិន៖ បាទ!ហ្នឹងកាលសម័យបីឆ្នាំ ស្រុកទើបកើតថ្មីទៀតច្រើនទេ ដូនកែវក៏ថ្មីដែរ ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ បូរីជលសារនេះក៏ថ្មីដែរ អង្គរបូរីដូចជាថ្មីដែរ បើព្រៃកប្បាសបានចាស់ ពីមុនចាស់តិចដែលទេស្រុក ខេត្តតាកែវទើបថ្មីច្រើនក្រោយទេ ។

ប៊ុនថន៖ ចឹងកាលហ្នឹងខាងតំបន់ហ្នឹងនៅខាងណាវិញ?

ហ៊ិន៖ បាទ ។

ប៊ុនថន៖ ពូមកកន្លែងតំបន់ហ្នឹងតែម្តង?

ហ៊ិន៖ បាទៗ !ខ្ញុំនៅតំបន់ហ្នឹងតែម្តង ។

ប៊ុនថន៖ ពូមន្ទីរតំបន់នៅស្រុកអីវិញ មន្ទីរតំបន់ហ្នឹង?

ហ៊ិន៖ កាលហ្នឹងមាននៅមន្ទីរណា ទាហានចេញមកទាហានតែម្តង ។

ប៊ុនថន៖ កាលហ្នឹងពូចេញមក តែនៅក្នុងខេត្តតាកែវទេ?

ហ៊ិន៖ បាទ ។

ប៊ុនថន៖ កាលហ្នឹងនៅជាមួយពីណាពូ?

ហ៊ិន៖ កាលហ្នឹងមេទ័ពកាលហ្នឹងស្លាប់តាំងពីសង្រ្គាមជិនាន់ហ្នឹង បើមេកងវរៈសេនាតូចអីឈ្មោះតា កប តា សុចអីតែស្លាប់អស់តាំងពីសង្រ្គាមឆ្នាំ៧៣ហ្នឹងណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ក្រោយមកមានមេផ្សេងទៀតហ្នឹងស្លាប់ទៅ មេពួកតាហឿន តា លាងអីគាត់ស្លាប់អស់ទៀតពួកហ្នឹងអត់មាននៅ ។

ប៊ុនថន៖ ចឹងគេផ្លាស់ផ្លូវរហូត?

ហ៊ិន៖ បាទ!ផ្លាស់ផ្លូវរហូត ចឹងហើយសង្រ្គាមចេះតែងាប់ចឹងទៅ មេងាប់មួយឡើងមួយបន្ត ។

ប៊ុនថន៖ បាទ!មានហាត់ទេពូកាលហ្នឹង?

ហ៊ិន៖ មានហាត់ដែរ ។

ប៊ុនថន៖ ហាត់មានរយៈពេលប៉ុន្មាន?

ហ៊ិន៖ ហាត់បានប៉ុន្មានខែដែរ វាយូរពេកហើយភ្លេចអស់ហើយ យូរដែលហាត់ខ្ទង់បីបួនខែដែលដឹង បានចេញទៅ ។

ប៊ុនថន៖ បានទៅវៃច្រើនកន្លែងដែលពូ?

ហ៊ិនៈ ខ្ញុំវិញនៅតែតាកែវ ភ្នំឌិនវិញពីរកន្លែងហ្នឹង កាលហ្នឹងពួកខ្ញុំចូលជិតនាទ៧៣ហ្នឹងមានទាហានខ្មែរខាងក្នុងនិងទាហានលន់ នល់ហ្នឹងដូចថាមូលតាមក្រុង១ហើយណាស់ មិនមែននៅនេះទេណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ វិញមូលហើយហ្នឹងណាស់ ។

ប៊ុនថនៈ នៅមូលទីរួមស្រុកនិងទីប្រជុំជន?

ហ៊ិនៈ ទីរួមស្រុកអត់មានទេ មានតែខេត្តទេកាលហ្នឹងនោះ តែអាភ្នំឌិននេះស្រុកដែលតែវានៅជាប់ជាមួយយួន ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ វាជាប់ជាមួយយួនវាពឹងទៅយួនកាលហ្នឹង យួននៅពីក្រោយនោះ ។

ប៊ុនថនៈ មានប៉ះគ្នាជាមួយយួនធៀវគីទេ?

ហ៊ិនៈ ប៉ះគ្នា ។

ប៊ុនថនៈ ចុះយួនវៀតកុងអីនោះ?

ហ៊ិនៈ យួនវៀតកុងយួនខាងជើងយួនជួយខ្មែរក្រហម ពួកធ្មេញខ្មៅពួកហានណូយ ។

ប៊ុនថនៈ បាទ!ចុះពូអត់មានដែលចូលរួមជាមួយវៀតកុងអី?

ហ៊ិនៈ អត់ទេ ។

ប៊ុនថនៈ រួមជាមួយគ្នាវិញខាងទាហានលន់ នល់អី?

ហ៊ិនៈ អត់ទេ ។

ប៊ុនថនៈ ចឹងវិញតែកំលាំងខ្មែរក្រហមសុទ្ធ?

ហ៊ិនៈ អត់មានចូលឡប់ឡូកគ្នាទេ កាលហ្នឹងនោះ ។

ប៊ុនថនៈ ចឹងពូនៅហ្នឹងរហូតដល់បែក?

ហ៊ិនៈ អត់ទេ មុនបែកខ្ញុំមកនៅភូមិភាគហើយខ្ញុំមកវិញនៅភ្នំពេញ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ នៅភ្នំពេញម្តុំព្រៃព្រីងអីនេះ ។

ប៊ុនថនៈ ព្រៃព្រីងនៅចោមចៅនេះ?

ហ៊ិនៈ បាទ!វិញពីហ្នឹងទៅកន្លែងដាំបាយកន្លែងស្នាក់នៅ កន្លែងកំពង់ត្រាំកំពង់អីនេះ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ កន្លែងអីគេហៅវត្តពោធិ វ៉ៃចេញពីដើមពោធិហ្នឹងចេញមកខាងកំបូលនេះ វ៉ៃកំពូលហ្នឹង វ៉ៃបានប៉ុន្មានថ្ងៃបែកទៅរំដោះភ្នំពេញទៅ ឡើងពីតំបន់ទៅ ។

ប៊ុនថនៈ ចឹងកាលហ្នឹងពូមួរពីទ័ពតំបន់មកកងទ័ពភូមិភាគវិញ?

ហ៊ិនៈ បាទ! កាលហ្នឹងឡើងមកទាំងកងវរៈ ។

ប៊ុនថនៈ កាលហ្នឹងវរៈប៉ុន្មានពូ?

ហ៊ិនៈ កាលខ្ញុំនៅតំបន់ហ្នឹងវរៈ«ត២» ។

ប៊ុនថនៈ ចឹងគេដាក់វរៈត២ចឹងតែម្តង?

ហ៊ិនៈ បាទៗ!ត២ចឹងតែម្តង ដល់ឡើងមកភូមិភាគកងវរៈ២៤ ។

ប៊ុនថនៈ វរៈ២៤វិញ?

ហ៊ិនៈ បាទ ។

ប៊ុនថនៈ កាលហ្នឹងពីណាដឹកនាំពូ?

ហ៊ិនៈ កាលហ្នឹងតា សឿងកាន់កងពល ដល់តា សឿងគាត់ផ្លាស់មកភូមិភាគឧត្តរទៅ ក្រោយមកឡើងមកតា វវៃអីខ្ញុំមិនសូវស្គាល់ផង សម័យនោះមិនមែនដូចសម័យយើងឥឡូវទេ យើងកូនទាហានហ្នឹង តែកងវរៈសេនាតូចយើងមិនស្គាល់មុខគេផង គ្រាន់តែស្គាល់ឈ្មោះៗចឹងទៅ ។

ប៊ុនថនៈ ចឹងកាលពូមកភូមិភាគហ្នឹងភូមិភាគនិរតីពូ?

ហ៊ិនៈ ភូមិភាគនិរតី ទេដល់រំដោះហើយបានគេបែកភូមិភាគហើយ ។

ប៊ុនថនៈ បាទ ។

ហ៊ិនៈ រំដោះភ្នំពេញហើយណាស់ ពួកខ្ញុំហ្នឹងគេបែកមកភូមិភាគបស្ចឹម ។

ប៊ុនថនៈ ចឹងភូមិភាគបស្ចឹមវិញ?

ហ៊ិនៈ បាទៗ!ភូមិភាគបស្ចឹម ភូមិភាគបស្ចឹមមកនេះខេត្តកំពង់ឆ្នាំង ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ភូមិភាគបស្ចឹមហ្នឹង ។

ប៊ុនថនៈ ភូមិភាគបស្ចឹមហ្នឹងពូមានបែកជាកងពលប៉ុន្មានទេពូ?

ហ៊ិនៈ អត់មាននេះដងនៅកងពល២៤ហ្នឹង តែដល់បែកមកឡើងមកកង៣០ប៉ុន្មានទេ កាលហ្នឹងភ្លេចហើយ៣៤អីមិនដឹងទេ អះ!កងវរៈ៣៤កងពលទី១ ។

ប៊ុនថនៈ កងពលទី១ហ្នឹងពីណាដឹកនាំពូ?

ហ៊ិនៈ កងពលទី១ហ្នឹង កាលរំដោះហើយតា លឹម តា លឹមហ្នឹងស្លាប់ហើយកាលរត់ឆ្នាំ៧៩ ស្លាប់បាត់ហើយ ។

ប៊ុនថន៖ អត់មានដូរណាគាត់នៅកាន់កាប់រហូត?

ហ៊ិន៖ គាត់កាន់កាប់រហូតដល់យួនចូលវៃហ្នឹងតែម្តងបែកគ្នាអស់ ។

ប៊ុនថន៖ ខាងភូមិភាគបស្ចិមហ្នឹងពីណាជាអ្នកគ្រប់គ្រង?

ហ៊ិន៖ កាលហ្នឹងតា ខ្ញុំមិនដែលឃើញមុខទេ ឈ្មោះតា ស៊ី តា ប៉ាល់ ខ្ញុំមិនដែលស្គាល់គេខ្ញុំឮតែឈ្មោះ ។

ប៊ុនថន៖ ជូ ចេតហៅស៊ីហ្នឹងមែនទេ?

ហ៊ិន៖ តា ស៊ី កាលជំនាន់ហ្នឹងគេថាគាត់ក្បាត់អីគេចាប់គាត់ដែលហ្នឹង ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ហើយតា ប៉ាល់ហ្នឹងមិនដឹងជាទៅណាទេ "អ្នកជិតនិយាយថា កាលហ្នឹងពួកហ្នឹងគេថាជាពលករវៀតណាមពួកហ្នឹងទៅរៀនស្រុកយួនទៅ ក្រោយ៧៥ហើយយួនមិនវៃយកកោះត្រល់ហ្នឹងស្លាប់មិនសូវបានទេ...." ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ កាលសម័យខ្មែរក្រហមកោះត្រល់អីកោះពោលៃអីហ្នឹងមិនយួនវៃ ឥឡូវយួនយកតើកោះត្រល់ហ្នឹង កោះពោលៃបានយើងនៅឥឡូវ ។

ប៊ុនថន៖ ចឹងពូកាលបែកភ្នំពេញហើយពូមកនៅណាវិញ?

ហ៊ិន៖ ខ្ញុំបែកភ្នំពេញហើយអង្គការឲ្យមកធ្វើការខាងរទេះភ្លើងនៅតាកែវ ។

ប៊ុនថន៖ ចឹងនៅតាកែវវិញ?

ហ៊ិន៖ ហ្នឹងហើយ នៅខេត្តតាកែវ ចប់ពីហ្នឹងទៅគេឲ្យមកនៅលង្វែក នៅបន្ទាយលង្វែក ។

ប៊ុនថន៖ មកបន្ទាយលង្វែក?

ហ៊ិន៖ បាទ!ចេញពីបន្ទាយលង្វែកហ្នឹងទៅ គេបញ្ជូនឲ្យមកកោះកុងព្រំដែនថៃហ្នឹង ទីរួមខេត្តកោះកុងពាល់ថ្ងៃហ្នឹង ។

ប៊ុនថន៖ បាទ ។

ហ៊ិន៖ ពួកខ្ញុំនៅទាល់តែយួនហ្នឹងវៃបានចេញ ។

ប៊ុនថន៖ កាលនៅលង្វែកហ្នឹងបានរយៈពេលប៉ុន្មាន?

ហ៊ិន៖ នៅលង្វែកហ្នឹងអត់បានមួយឆ្នាំផង ។

ប៊ុនថន៖ កាលនៅហ្នឹងធ្វើអីវិញ?

ហ៊ិន៖ កាលទៅហ្នឹងអត់មានធ្វើអីផង កាលហ្នឹងអត់ទាន់មានការងារអីធ្វើ កាលហ្នឹងទៅខែប្រាំងដែលហើយណាស់ ។

ប៊ុនថន: បាទ ។

ហ៊ិន: ដល់ហើយបានបញ្ជូនមកកោះកុងមក មកកោះកុងមកធ្វើស្រែកាប់ចំការធម្មតាដូចថាគេឲ្យធ្វើដំណាំហូបខ្លួនឯងធ្វើស្រែហូបខ្លួនឯងហ្នឹងណាស់ ។

ប៊ុនថន: បាទ ។

ហ៊ិន: កាលជំនាន់ហ្នឹងគេម៉េចឲ្យយើងនៅស្ងៀមដោះស្រាយជីវភាពខ្លួនឯង ។

ប៊ុនថន: តែកាលពូមកកោះកុងហ្នឹងពូនៅអន្តភាពដដែលទេ?

ហ៊ិន: កាលហ្នឹងខ្ញុំនៅទ័ពរហូត ។

ប៊ុនថន: បាទ!ដល់ពេលយួនចូលមកហ្នឹងពូរត់ទៅណាវិញ?

ហ៊ិន: កាលយួនចូលមកហ្នឹងរត់មកនៅម្តុំខដុងអីហ្នឹង ខេត្តកំពង់ស្ពឺអីហ្នឹងហើយឡើងមកខេត្តកំពង់ឆ្នាំងនៅវៃជាមួយយួនហ្នឹងហើយ យូរៗទៅវាអស់អីទប់ទៅចូលព្រៃទៅចូលទៅខាងទន្លេសាបដល់ទន្លេសាបខ្ញុំទៅផ្ទះ ទៅស្រុកវិញទៅ ។

ប៊ុនថន: បាទ ។

ហ៊ិន: ទៅដល់ពេលការហើយហ្នឹងខ្ញុំបានមកនៅជាមួយពូនៅព្រៃមាន់នេះវិញ ។

ប៊ុនថន: កាលទៅនៅស្រុកបានប៉ុន្មានឆ្នាំ?

ហ៊ិន: នៅបានពីរបីឆ្នាំដែរ តាំងពី៨១ដល់៨៣បានខ្ញុំមកព្រៃមាន់វិញ ។

ប៊ុនថន: យ៉ាងម៉េចបានជាពូត្រឡប់មកខាងព្រៃមាន់នេះវិញ?

ហ៊ិន: មកជាមួយពូវិញ មកជាមួយគាត់វិញ នៅហ្នឹងដីងរកស៊ីអីកាលឆ្នាំ៨២ហ្នឹង មកនៅនេះវិញកាលហ្នឹងចេញចូលបានគេមកហូរហែរមកទៅ ។

ប៊ុនថន: ចឹងបងប្អូនពូមានមកជាមួយពូទេ?

ហ៊ិន: អត់ទេ មកតែខ្ញុំទេ ។

ប៊ុនថន: មកនៅហ្នឹងរហូតដល់សមាហរណ៍កម្ម?

ហ៊ិន: បាទ ។

ប៊ុនថន: ចឹងចង់សួរពូមួយទៀត កាលមុនសមាហរណ៍កម្មធ្លាប់បើករបបអីចឹង ក្រោយសមាហរណ៍កម្មហើយឈប់បើកហើយឬនៅបើកដដែល?

ហ៊ិន: ឈប់ហើយសព្វថ្ងៃធ្វើស្រែអីហូបខ្លួនឯង ។

ប៊ុនថន: ចឹងចង់សួរថាការរស់នៅហ្នឹងជីវភាពអីរស់នៅយ៉ាងម៉េចដែរមុននិងក្រោយ?

ហ៊ិន: កាលគេនៅបើកឲ្យយើងមិនសូវនឿយរកស្រួលដែលហ្នឹង ដល់គេមិនបើកឲ្យទាល់តែខំទៅគេបើកឲ្យក៏គេប្រើយើងអីដែរ ដូចជាដឹកជញ្ជូនអីទៅ ដល់ចប់សង្គ្រាមហើយសមាហរណ៍

កម្មហើយគេមានដឹកជញ្ជូនទៅណាទៀត គេមានបើកអីគេនៅជាទាហានគេបើកដែលហ្នឹងយើងជាប្រជាជនយើងអត់ ។

ប៊ុនថន: បាទ ។

ហ៊ិន: យើងធ្វើស្រែធ្វើអីដាំពោត ដាំដំឡូងអីចឹងទៅហូបរាល់ថ្ងៃចឹងទៅ ទិញអង្ករហូបទៅ អាឈើអីមានរទេះគោដឹកឈើអី ស៊ីឈ្នួលដឹកឲ្យគេទៅ មួយជើង៨ទៅ៥០០ទៅទិញអង្ករជំនាន់ហ្នឹងមួយការ៉ុងប៉ុន្មានអង្ករថៅក៣០០-២០០អីហ្នឹង ។

ប៊ុនថន: ចឹងដូចជាឈើអីអស់នៅឆ្នាំណា?

ហ៊ិន: ឈើអស់យូរហើយ កាលឆ្នាំ២០០០ហ្នឹងអស់ ។

ប៊ុនថន: កាលមុនមានព្រៃដល់អស់ព្រៃនៅឆ្នាំ៩០ប៉ុន្មាន កាលឆ្នាំ៩០អីនៅពូ?

ហ៊ិន: នៅទេ ទើបអស់ឆ្នាំ២០០០ហ្នឹង ។

ប៊ុនថន: កាប់ធ្វើផ្ទះ?

ហ៊ិន: ខ្លះដូចថាដីគេចឹងទៅ គេកាប់យកដីចឹងទៅណាស់ "ស្តាប់មិនសូវបាន....."កន្លែងខ្លះការពារមិនបានចឹងទៅ ។

ប៊ុនថន: ចឹងពូសព្វថ្ងៃមានកូនប៉ុន្មាននាក់?

ហ៊ិន: មានបីនាក់ ។

ប៊ុនថន: ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ហ៊ិន: ប្រុសទាំងបី ។

ប៊ុនថន: នៅរៀនទេពូ?

ហ៊ិន: នៅរៀនមួយការហើយពីរ ។

ប៊ុនថន: រៀនថ្នាក់ទីប៉ុន្មានដែរ?

ហ៊ិន: កូនអាមួយបងហ្នឹងរៀនតិចដែលថ្នាក់ទី៥ ថ្នាក់៥ជំនាន់មុនវាចេះដែរ ។

ប៊ុនថន: បាទ ។

ហ៊ិន: ហើយអាមួយទៀតការហើយនេះអាហ្នឹងជាប់បាក់ឌុបធ្វើជាគ្រូបង្រៀនហើយអាមួយនេះប្រឡងបាក់ឌុបមិនជាប់រៀនបន្តទៀត ។

ប៊ុនថន: បាទ!ចឹងខ្ញុំអរគុណពូហើយ ។

ហ៊ិន: បាទ ។

**«ចប់»**